ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធនធានទឹក និង ឧតុនិយម

លេខ ៦៩៩ សរណន ធទឧ

# សារាចរណែនាំ

## ស្តីអំពី

## វិធានការទប់ទល់គ្រោះរាំងស្ងួតក្នុងរដូវវស្សា និងត្រៀមលក្ខណៈ សំរាប់ស្រូវប្រាំងចេញទឹក និងស្រូវប្រាំង ឆ្នាំ 2001 – 2002

ក្នុងឆ្នាំ 2001 នេះ ស្ថានភាពអាកាសធាតុមានការប្រែប្រួលខុសប្រក្រតី ទន្ទឹមនេះការគ្រប់គ្រងធនធានទឹក នៅតំបន់ដីសណ្តកម្ពុជា-វៀតណាមពុំបានល្អប្រសើរ ដែលជាហេតុធ្វើឱ្យតំបន់ទំនាបមួយចំនួន នៃព្រះរាជាណាចក្រ កម្ពុជាដែលពុំធ្លាប់លិចប្រែក្លាយជាលិច និងតំបន់មួយចំនួនទៀតដែលត្រូវលិចក្នុងរយៈពេលខ្លី បែរជាលិចក្នុង រយៈពេលយូរដោយល្បឿននៃការស្រកយឺត។ ដោយឡែក តំបន់ខ្ពង់រាបមួយចំនួនទៀតបែរជារងគ្រោះដោយ, ការរាំងស្ងួតទៅវិញក្នុងអំឡុងនៃខែកក្កដា ដែលមានរយៈពេលប្រមាណពី 15ថ្ងៃ ទៅ 27ថ្ងៃ។ ការកើតឡើង នៃគ្រោះធម្មជាតិទាំងពីរនេះ បានធ្វើឱ្យប៉ះពាល់ដល់ជីវភាពរស់នៅរបស់ប្រជាកសិករ ខូចខាតទ្រព្យសម្បត្តិ ប្រជាពលរដ្ឋ និងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តជាច្រើន។

យោលទៅលើសភាពការណ៍ជាក់ស្តែងខាងលើនេះ ក្រសួងបានចេញសារាចរណែនាំជាបន្តបន្ទាប់រួចហើយ។ ដើម្បីបង្កើនប្រសិទ្ធភាពនៃវិធានការ ក្រសួងសូមធ្វើការរំលឹកឡើងវិញ និងបន្ថែមនូវការណែនាំមួយចំនួនទៀត ជូនដល់គ្រប់មន្ទីរធនធានទឹក និងឧតុនិយមខេត្ត-ក្រុង ដូចខាងក្រោម÷

1. យកចិត្តទុកដាក់ក្នុងការទប់ភ្លឺស្រែឱ្យបានគត់មត់ និងថែទាំជាប្រចាំដើម្បីរក្សាទឹកទុកក្នុងស្រែឱ្យបាន ក្នុងកំរិតអតិបរមា ជៀសវាងការខ្វះខាតទឹកទាំងស្រុងនាចុងរដូវវស្សា។

2. ចាត់ចែង និងត្រៀមលក្ខណៈបិទទ្វារទឹកទំនប់អាង ដើម្បីតំកល់ទឹកទុកសំរាប់បំរើឱ្យការស្រោចស្រព។

3. បង្កើនកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរមូលដ្ឋាន :

+ ក្នុងការប្រើប្រាស់មធ្យោបាយ សំភារៈ ឧបករណ៍បូមបាច ជាពិសេសម៉ាស៊ីនបូមទឹកដែលមាននៅមូលដ្ឋានស្រាប់សំរាប់អន្តរាគមន៍ពេលជួបគ្រោះរាំងស្ងួត ។

+ ទប់ស្កាត់ឱ្យខាងតែបាន នូវរាល់សកម្មភាពជនទាំងឡាយណា ដែលបង្កឱ្យមានការខូចខាតដល់សំណង់ធារាសាស្ត្រ ដូចជាការកាប់ភ្លឺស្រែ ប្រឡាយ ឬគាស់បង្ហើបទ្វារទឹកដើម្បីដាក់ឧបករណ៍នេសាទ និងសកម្មភាពផ្សេងៗទៀតធ្វើឱ្យរាំងស្ទះដល់ការងារបង្កបង្កើនផល ។

4. រៀបចំឱ្យបានល្អនូវកិច្ចដំណើរការ និងការថែទាំសំណង់ធារាសាស្ត្រ ដើម្បីឈានទៅបង្កើតសហគមន៍កសិករប្រើប្រាស់ទឹក ។

ទទួលបានសារាចរណែនាំនេះ គ្រប់មន្ទីរធនធានទឹក និងឧតុនិយមខេត្ត-ក្រុង ត្រូវខិតខំអនុវត្តតាមខ្លឹមសារខាងលើឱ្យបានលទ្ធផលល្អប្រកបដោយភាពម៉ឺងម៉ាត់ និងស្មារតីទទួលខុសត្រូវខ្ពស់ ។

ភ្នំពេញ ថ្ងៃទី ១៤ ខែ ១១ ឆ្នាំ ២០០១

រដ្ឋមន្ត្រី

លឹម គានហោ

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- សាលាខេត្ត-ក្រុង
- នាយកដ្ឋានក្រោមឱវាទក្រសួង

" ដើម្បីជូនជ្រាប "

- ឯកសារ - កាលប្បវត្តិ